Ottawa County Health Department

# សន្លឹកព័ត៌មានសាធារណៈ

## គ្រុន Q [Q FEVER]

### តើគ្រុន Q  គឺជាអ្វី?

គ្រុន Q គឺជាជម្ងឺឆ្លងមួយ ដែលឆ្លងពីសត្វ ទៅមនុស្ស ។ វាបង្ក ដោយបាក់តេរីមួយរស់នៅក្នុងសត្វគោ ចៀម ពពែ ហើយត្រូវបាន រកឃើញ ក្នុងសត្វពាហនៈមួយចំនួនទៀត ។

សត្វមានមេរោគនេះ មិនមែនឈឺគ្រប់គ្នាទេ ។ ប៉ុន្តែពួកវាបញ្ចេញ បាក់តេរីនៅក្នុងទឹកដោះ ទឹកនោម លាមក និងទឹកសុករបស់វា ។ គ្រុន Q អាចទប់ទល់នឹងកំដៅ ការហាលឱ្យស្ងួត  ហើយនិងវិធី សម្លាប់មេរោគសាមញ្ញជាច្រើនទៀត ។

### តើគ្រុន Q សម្បូរប៉ុណ្ណា?

មនុស្សស្រួលឆ្លងគ្រុន Q ណាស់ ពីព្រោះវាសម្បូរណាស់ ក៏ប៉ុន្តែវា កម្រត្រូវគេរាយការណ៍ ដោយសារក្នុងករណីជាច្រើន ជម្ងឺស្រាល ពេក ។

### តើគ្រុន Q ត្រូវបានឆ្លងយ៉ាងដូចម្តេច?

- គ្រុន Q អាចឆ្លងបាន តាមរបៀបទាំងឡាយខាងក្រោម នេះ:
- ដកដង្ហើមចូល នូវបាក់តេរីពីធូលីហុយនៅកសិដ្ឋាន ដែល មានធាតុសល់ពីកំណើតកូនសត្វ
- ខ្យល់អាចបក់ធូលីនេះ អស់ចំងាយកន្លាស់ម៉ៃល៏ ឬឆ្ងាយ ជាង
- ផឹកទឹកដោះ ដែលមានមេរោគ
- ក្អួត និងដកដង្ហើមចូល នូវអាហារដែលមានមេរោគក្នុងវា (កម្រជាង)

ការឆ្លងពីមនុស្ស ទៅមនុស្ស នៃមេរោគប្រ៊ូសេឡូស៊ីស កម្រមាន មែនទែន ។

### តើអាចមានរោគសញ្ញាអ្វីខ្លះ?

មនុស្សអាចកើតគ្រុន Q ដោយមិនដឹងខ្លួន ឬមួយគេអាចស្មាន ច្រឡំថាកើតគ្រុនធម្មតា ។ អ្នកខ្លះកើតរោគសញ្ញាភ្លាម ។ រយៈពេល សម្ងំរបស់បាក់តេរីគ្រុន Q គឺពី 14 ថ្ងៃ ទៅ 21 ថ្ងៃ ។

រោគសញ្ញាទូទៅអាចមានរួមទាំង:

- ក្តៅខ្លួនខ្លាំង
- រងា និងបែកញើស
- ឈឺក្បាល និងសាច់ដុំ
- ឈឺបំពង់ក
- លែងចង់បរិភោគអាហារ
- ក្អក
- ក្អួត និងអារម្មណ៍ចង់ក្អួត
- រាគអាចម៏
- ឈឺពោះ
- ឈឺដើមទ្រូង

អ្នកខ្លះអាចកើតរោគហើមសួត ឬរោគថ្លើម ។ អ្នកភាគច្រើននឹងមាន ដំណើរថ្លើមដ៏ខុសប្រក្រតី ។

### តើគ្រុន Q ត្រូវបានវិនិច្ឆ័យរោគយ៉ាងដូចម្តេច?

គ្រុន Q ត្រូវបានពិនិត្យឃើញ ដោយពិនិត្យឈាម ។

### តើគ្រុន Q ត្រូវបានព្យាបាលយ៉ាងដូចម្តេច?

ជារឿយៗ ថ្នាំអង់ទីប៊ីយ៉ូទិកត្រូវបានប្រើដើម្បីព្យាបាលគ្រុន Q ហើយ មនុស្សភាគច្រើនជាសះស្បើយយ៉ាងឆាប់ ។ ធម្មតា អ្នកដែលមិនស្វែង រកការព្យាបាល នោះនឹងជាក្នុងរយៈពេលបួនដប់ខែ ។

### សម្រាប់ព័តិមានបន្ថែមអំពីគ្រុន Q ទាក់ទង:

Ottawa County Health Department
www.miOttawa.org

Center for Disease Control and Prevention
www.bt.cdc.gov/agent/ Qfever/
ទូរស័ព្ទ:: (888) 246-2675

12251 James St., Suite 400
Holland, MI  49424
ទូរស័ព្ទ: (616) 396-5266
ទូរសារ:  (616) 393-5643
វ៉ិបសាយ: www.miOttawa.org